# សុន្ទរកថា

## របស់ លោកជំទាវ នាង ចាន់ថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា

## ក្នុងសន្និសីទសេដ្ឋកិច្ចវិទូ ~ ខេត្តសៀមរាប ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០៩

**ជាបឋម ខ្ញុំសូមគោរព :**

- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស និងអង្គប្រជុំតុមូល ជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយ ដោយបានចូលរួមក្នុងវេទិកាដ៏មានសារសំខាន់នេះ នៅលើប្រធានបទមួយនិងក្នុងពេលវេលាដ៏សមស្រប ក្រោមអធិបតីភាពដ៏ឧត្តុងឧត្តមពីសំណាក់ **សម្តេចអគ្គ~មហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងភ្ញៀវឥសរជនទាំងឡាយ ដែលជាកតាលីករដ៏ចំបងនៃកំណែទម្រង់ប្រទេសកម្ពុជា ខណៈដែលយើងកំពុងឆ្លងកាត់ដំណាក់កាលដ៏លំបាកនាពេលនេះ ។

ជាកិច្ចចាប់ផ្តើម ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនអង្គប្រជុំថា បេសកកម្មចំបងរបស់ធនាគារជាតិនៃកម្ពុជា គឺរក្សាថ្លៃឱ្យមានស្ថិរភាព និងអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយដ៏រឹងមាំ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចទូលំទូលាយប្រកបដោយចីរភាព ។

<u>ហេតុដូចនេះ ខ្ញុំសូមឈានចូលបញ្ហាទីមួយដែលបានលើកឡើងថា :</u> <u>**តើត្រូវធ្វើបែបណាដើម្បីទប់ទល់នឹងកំណើនអតិផរណា និងការកើនឡើងថ្លៃទំនិញ ពិសេសថ្លៃប្រេង ?**</u>

ជាទូទៅ គោលនយោបាយរូបិយវត្ថុព្យាយាមឆ្លើយតបចំពោះសម្ពាធអតិផរណាដែលមានប្រភពពីកំណើនតំរូវការជាជាងបណ្តាលមកពីបញ្ហាផ្គត់ផ្គង់ ។ ដូចនេះ ចាំបាច់ត្រូវមានការយល់ដឹងច្បាស់លាស់ពីមូលហេតុនៃការឡើងថ្លៃទំនិញ ។ ចំពោះកម្ពុជា សេដ្ឋកិច្ចយើងបានប្រឈមនឹងសម្ពាធអតិផរណាដ៏ខ្លាំងចាប់តាំងពីខែធ្នូ ឆ្នាំ២០០៧មក នៅពេលដែលអត្រាអតិផរណាឆ្នាំលើឆ្នាំកើនឡើងដល់កម្រិតពីរខ្ទង់ជាថ្មីម្តងទៀត បន្ទាប់ពីបានជួប

លើកដំបូងក្នុងអំឡុងវិបត្តិអាស៊ី ឆ្នាំ១៩៩៧-១៩៩៨ ។ ថ្លៃម្ហូបអាហារ និងជាពិសេសថ្លៃថាមពលលើទីផ្សារអន្តរជាតិ ដែលរងការកើនឡើងយ៉ាងខ្លាំងជាលំដាប់ បានបង្កសម្ពាធអតិផរណាស្ទើរទូទាំងពិភពលោក ។ ដោយសារកម្ពុជាជាប្រទេសមានទំហំតូច និងមានសេដ្ឋកិច្ចបើកចំហរ សេដ្ឋកិច្ចងាយរងឥទ្ធិពលជាពិសេសពីការវិវឌ្ឍន៍ថ្លៃអន្តរជាតិ ហើយដោយសារភាពពឹងផ្អែកទាំងស្រុងលើការផ្គត់ផ្គង់ប្រភពថាមពលពីក្រៅប្រទេសទៀតនោះការវិវឌ្ឍន៍ នៃថ្លៃបែបនេះពិតជាមានឥទ្ធិពលជាខ្លាំងចំពោះនិន្នាការអតិផរណារបស់ប្រទេសយើង ។ អត្រាអតិផរណាប្រចាំឆ្នាំ បានឡើងដល់កម្រិតកំពូល ២៥.៧% នៅខែឧសភា ឆ្នាំ២០០៨ ។ ថ្លៃម្ហូបអាហារដែលជាកត្តាចម្បងនាំឱ្យមាន អតិផរណា បានកើនឡើង ៤៩% នៅអំឡុងពេលជាមួយគ្នានោះ ។

ទន្ទឹមនោះ កំណើនរូបិយវត្ថុដ៏ខ្ពស់ជាងការរំពឹងទុក ដែលជាលទ្ធផលនៃលំហូរចូលទុនយ៉ាងច្រើនជាបន្តបន្ទាប់ និងនៃជោគជ័យក្នុងការគ្រប់គ្រងសេដ្ឋកិច្ចនាទសវត្សកន្លងមកនេះ ត្រូវបានចាត់ទុកថាជាកត្តារួមចំណែកមួយក្នុងកំណើនអតិផរណាផងដែរ ។ ស្ថានភាពនេះបានជម្រុញឱ្យមានការគ្រប់គ្រងប្រកបដោយភាពប្រុងប្រយ័ត្នលើលក្ខខណ្ឌរូបិយវត្ថុ ដើម្បីឱ្យនយោបាយរូបិយវត្ថុមានលទ្ធភាពប្រសើរក្នុងការឆ្លើយតបនឹងហានិភ័យអតិផរណាខ្ពស់ ។ ការអនុវត្តគោលនយោបាយរូបិយវត្ថុបានផ្តោតលើការគ្រប់គ្រងស្ថានភាពសំណល់សាច់ប្រាក់ងាយស្រួល និងការជៀសវាងការពាក់ព័ន្ធហួសប្រមាណរបស់ធនាគារពាណិជ្ជនៅក្នុងវិស័យអចលនទ្រព្យដែលអាចមានផលមិនល្អដល់ពួកគេ ។ ធនាគារជាតិនៃកម្ពុជាបានដាក់ចុះនូវគោលនយោបាយរឹតត្បិតមួយចំនួនជាកញ្ចប់ ដើម្បីទប់ស្កាត់ការកើនឡើងសកម្មភាពឥណទាន និងកាត់បន្ថយកំណើនរូបិយវត្ថុ ដែលក្នុងនោះរួមមាន ការបង្កើនប្រាក់បំរុងកាតព្វកិច្ច ពី ៨% ទៅ ១៦% និងកំណត់ពិដានឥណទាន ១៥% ចំពោះវិស័យអចលនទ្រព្យ លើធនាគារពាណិជ្ជ ។

ប៉ុន្តែ ហានិភ័យអតិផរណាខ្ពស់ដែលបណ្តាលពីកំណើនថ្លៃប្រេងឥន្ធនៈ ហើយប្រសិនមាននិន្នាការយូរអង្វែងគឺជាបញ្ហាប្រឈមដ៏ធំចំពោះកម្ពុជាដែលជាប្រទេសនាំចូលប្រេងឥន្ធនៈ ។ គោលនយោបាយរូបិយវត្ថុចាំបាច់ត្រូវមានលក្ខណៈទន់ភ្លន់ និងត្រូវប្រុងប្រយ័ត្នចំពោះឥទ្ធិពលបន្ទាប់នៃកំណើនថ្លៃ ។ ទន្ទឹមនោះ ក៏ចាំបាច់ត្រូវទ្រទ្រង់វិធានការអន្តរាគមន៍របស់រដ្ឋាភិបាលផងដែរ ដើម្បីដោះស្រាយបញ្ហាផ្គត់ផ្គង់ដោយផ្ទាល់ ជាពិសេសចំពោះករណីការឡើងថ្លៃម្ហូបអាហារសំខាន់ៗ ។ ការខិតខំពង្រឹងបណ្តាញមីក្រូហិរញ្ញវត្ថុ និងការជំរុញការប្រើប្រាស់សេវាធនាគារចំពោះសហគ្រាសធុនតូចនិងមធ្យម ក៏ដូចជាចំពោះកសិករ នឹងបន្តនៅតែជាគោលការណ៍ចំបងមួយនៃគោលនយោ-បាយរូបិយវត្ថុ ។

<u>ឯកឧត្តម លោកជំទាវ លោក លោកស្រី !</u>

<u>ខ្ញុំសូមអនុញ្ញាតផ្តល់មតិមួយចំនួនលើសំណួរ : **តើសេដ្ឋកិច្ចកម្ពុជាត្រៀមខ្លួនចេញពី "ដុល្លាររូបនីយកម្ម" ឬនៅ ហើយការនេះមានន័យដូចម្តេចសម្រាប់អាជីវកម្ម?**</u>

ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅកម្ពុជាបានចាប់ផ្តើមប្រមាណជាងមួយទសវត្សមកហើយ ។ គួរកត់សម្គាល់ថា ការប្រើប្រាស់នេះមិនមែនជាលទ្ធផលនៃសេចក្តីសម្រេចនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាទេ ប៉ុន្តែជាការឆ្លុះបញ្ចាំងនូវការនិយមរបស់អ្នកប្រើប្រាស់ ក្នុងកាលៈទេសៈដែលប្រទេសប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចនាពេលនោះ ។ នៅពេលប្រជាជនស្គាល់និងស៊ាំនូវភាពងាយស្រួលក្នុងការប្រើប្រាស់រូបិយប័ណ្ណខ្លាំង នោះដំណើរការបកក្រោយនឹងពិបាក សូម្បីតែបន្ទាប់ពីលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចមានភាពប្រសើរឡើងក៏ដោយ ពោលគឺត្រូវចំណាយពេលវេលាយូរដើម្បីកែប្រែឥរិយាបទរបស់ប្រជាជន។

ក្នុងរយៈកាលកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងគ្រប់គ្រងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ក្នុងគោលបំណងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ និងបង្កើនសមាមាត្រការប្រើប្រាស់លុយរៀលឱ្យកាន់តែមានទំហំធំឡើង និងរលូន ក្នុងសកម្មភាពសេដ្ឋកិច្ច ។ ទោះបីការវិវត្តហាក់ដូចជាមានភាពយឺតយ៉ាវសំរាប់អ្នកសង្កេតការសេដ្ឋកិច្ចក៏ដោយ វាក៏បានបញ្ជាក់ថា ១) សកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាបានធ្វើឱ្យតម្លៃប្រាក់រៀលមានស្ថិរភាពធៀបប្រាក់ដុល្លារ និង ២) សូម្បីតែនៅទីក្រុង ប្រាក់រៀលក៏ត្រូវបានគេប្រើប្រាស់យ៉ាងពេញលេញ ក្នុងសកម្មភាពប្រចាំថ្ងៃ និងយកតាមអត្រាប្តូរប្រាក់បច្ចុប្បន្នទៀតផង ។ លើសពីនេះទៅទៀត គំលាតនៃការទិញ និងលក់ ឬកម្រៃជើងសារ កាន់តែមានទំហំតូចទៅៗ ដែលបង្ហាញពីជំនឿទុកចិត្តកាន់តែខ្លាំងឡើងលើរូបិយវត្ថុជាតិយើង និងលើសកម្មភាពធនាគារកណ្តាលក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ជាក់ស្តែងធៀបនឹងលុយដុល្លារ ។

របបរូបិយវត្ថុបច្ចុប្បន្នមានឥទ្ធិពលផ្សេងគ្នាចំពោះអ្នកប្រើប្រាស់និងអាជីវកម្មនីមួយៗ ដោយអាស្រ័យទៅលើរូបិយប័ណ្ណចារឹកនៃប្រាក់ចំណូលឬប្រតិបត្តិការអាជីវកម្មរបស់ពួកគេ ។ ដូច្នេះ ខ្ញុំសូមឆ្លើយសំណួរដែលបានលើកសួរនោះដោយសំណួរមួយទៀតថា : តើរហូតដល់ពេលនេះការប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងសេដ្ឋកិច្ចកម្ពុជាបង្កបញ្ហាចំពោះអ្នកប្រើប្រាស់ និងអាជីវកម្មក៏វិតណា? ចំពោះទិដ្ឋភាពម៉ាក្រូ មតិភាគច្រើនទទួលស្គាល់ថាដុល្លារូបនីយកម្មមានគុណសម្បត្តិគួរឱ្យកត់សម្គាល់ក្នុងការស្តារបនា និងទ្រទ្រង់ស្ថិរភាពសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុជាតិដ៏រឹងមាំតាមរយៈការជំរុញរូបិយវត្ថុនីយកម្មឡើងវិញ និងការបន្ស៊ីជំរៅហិរញ្ញវត្ថុ ។ តែទន្ទឹមនោះ គេក៏ពុំអាចបដិសេធនូវគុណវិបត្តិនៃការប្រើប្រាស់ដុល្លារ ដូចជា ការខាតបង់ផលអំពីការចេញផ្សាយក្រដាសប្រាក់ និងឧបសគ្គចំពោះគោលនយោបាយរូបិយវត្ថុ ជាដើមដែរ ។

បច្ចុប្បន្ន ដោយសាររលកនៃវិបត្តិហិរញ្ញវត្ថុបានរាលដាលដល់ប្រទេសជាច្រើនលើពិភពលោក ដំណើរស្វែងរកគុណភាពបានបង្កើនការនិយមរបស់ភ្នាក់ងារសេដ្ឋកិច្ចលើប្រាក់ដុល្លារអាមេរិក ។ ផ្អែកលើកត្តាទាំងឡាយនេះ បទពិសោធន៍នៃប្រទេសដុល្លារូបនីយកម្មជាច្រើនលើពិភពលោកបានបង្ហាញថា បដិដុល្លារូបនីយកម្មមិនអាចសំរេច

បានដោយនីតិកម្មតឹងរ៉ឹងទេ ប៉ុន្តែតំរូវឱ្យមានការបង្កើតបរិស្ថានមួយដែលអំណោយផលដល់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកពីសំណាក់សាធារណជន និងអាជីវករ ។

ដូច្នេះ ខ្ញុំយល់ថា អ្វីសំខាន់ដែលចាំបាច់ត្រូវធ្វើនាពេលនេះគឺ ការបន្តពង្រឹងស្ថានភាពសារពើពន្ធ និងប្រព័ន្ធធនាគារ ព្រមទាំងខិតខំលើកកំពស់មូលដ្ឋានគ្រឹះរបស់សេដ្ឋកិច្ចឱ្យបានរឹងមាំថែមទៀត មុនពេលធ្វើការផ្លាស់ប្តូររបបរូបិយវត្ថុ ។

**ចំណុចជាបន្តគឺសំណួរថា តើកម្ពុជាកំពុងធ្វើអ្វីខ្លះដើម្បីទាក់ទាញវិនិយោគលើវិស័យហិរញ្ញវត្ថុ?**

ខ្ញុំសូមផ្តោតលើកត្តាបី ៖ ការបើកចំហវិស័យហិរញ្ញវត្ថុ តួនាទីរបស់ធនាគារកណ្តាលជាអាជ្ញាធររូបិយវត្ថុ និងអាណាព្យាបាល និងកំណែទំរង់វិស័យហិរញ្ញវត្ថុ ។

ទីមួយ សេរីភាវូបនីយកម្មហិរញ្ញវត្ថុគឺជាកត្តាគន្លឹះមួយក្នុងការទាក់ទាញវិនិយោគ ។ កម្ពុជាមានរបបវិនិយោគបើកទូលាយ ដែលក្រសោបទាំងវិស័យហិរញ្ញវត្ថុផងដែរ ។ កន្លងមក យើងបានយកចិត្តទុកដាក់ក្នុងការផ្តល់ច្រកចូលទីផ្សារ និងប្រព្រឹត្តកម្មជាតិដល់វិនិយោគិនបរទេស ដូចជា ការអនុញ្ញាតនូវកម្មសិទ្ធិបរទេស១០០% ក្នុងករណីអនុលោមតាមលក្ខខណ្ឌអាជ្ញាប័ណ្ណដែលមានលក្ខណៈដូចគ្នាចំពោះវិនិយោគិនជាតិ និងបរទេស ។ បច្ចុប្បន្នប្រទេសកម្ពុជាបានក្លាយជាលំនៅដ្ឋានស្រាប់ទៅហើយ សំរាប់សាខានិងក្រុមហ៊ុនសម្ព័ន្ធញាតិរបស់ធនាគារបរទេសប្រហែល១០ ។ ទ្រព្យសកម្មសរុប និងមូលនិធិភាគទុនិករបស់សាខានិងក្រុមហ៊ុនសម្ព័ន្ធញាតិរបស់ធនាគារបរទេសនេះ មានកំរិត ៤៦% និង ៣៨% រៀងគ្នា ធៀបនឹងទ្រព្យសកម្មនិងមូលនិធិភាគទុនិកសរុបរបស់ប្រព័ន្ធធនាគារ ។

ទីពីរ ក្នុងវិស័យហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងអាណាព្យាបាលកំពុងខិតខំព្យាយាមក្នុងការក្លាយខ្លួនជានិយ័តករដ៏រឹងមាំ និងក្នុងការប្រតិបត្តិប្រកបដោយតម្លាភាព ។ យើងនឹងជំរុញថា គោលនយោបាយហិរញ្ញវត្ថុ ក្របខ័ណ្ឌបទប្បញ្ញត្តិ នីតិវិធី និងវិធានការដែលទាក់ទងនឹងអ្នកផ្គត់ផ្គង់ និងទីផ្សារសេវាហិរញ្ញវត្ថុ ត្រូវបានដាក់បង្ហាញ និងពន្យល់បកស្រាយជាសាធារណៈ មុនពេលដាក់អនុវត្តឱ្យប្រើប្រាស់ ។ ទន្ទឹមនោះ យើងក៏បានផ្តល់តម្លៃយ៉ាងខ្ពស់ផងដែរ ដល់ការផ្លាស់ប្តូរយោបល់និងទស្សនៈជាមួយវិស័យឯកជន ដោយផ្អែកលើទំនុកចិត្ត និងកិច្ចសហការជិតស្និទ្ធ ។

ទីបី ធនាគារជាតិមានការយល់យ៉ាងច្បាស់នូវសារៈសំខាន់នៃសេវាហិរញ្ញវត្ថុសំរាប់ដំណើរសេដ្ឋកិច្ចទាំងមូល ។ ម្យ៉ាងទៀត ប្រព័ន្ធហិរញ្ញវត្ថុដែលដំណើរការល្អ គឺត្រូវផ្អែកលើជន្ទល់ច្បាប់ និងបទប្បញ្ញត្តិ ដែលសំដៅជំរុញលើកទឹកចិត្តផ្នែកឯកជន និងបង្កបរិយាកាសល្អចំពោះប្រតិបត្តិការទីផ្សារ តាមរយៈការកាត់បន្ថយហានិភ័យ និងចំណាយប្រតិបត្តិការធនាគារ ។

ស្ថិតក្រោមស្មារតីនេះ មានការរំពឹងទុកថា កំណែទម្រង់ហិរញ្ញវត្ថុដែលបាននិងកំពុងអនុវត្ត ដូចមានចែងនៅក្នុង**ផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈកាលវែង** ដែលត្រូវបានអនុម័តឆ្នាំ២០០១ ហើយត្រូវបានធ្វើបច្ចុប្បន្ន-កម្មនៅឆ្នាំ២០០៧ នឹងធ្វើឱ្យអន្តរការិយកម្មហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព តាមរយៈការលើកកំពស់ហេដ្ឋា-រចនាសម្ព័ន្ធច្បាប់និងហិរញ្ញវត្ថុ និងការបង្កើនការប្រកួតប្រជែងក្នុងចំណោមបណ្តាធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ។

ការលើកទឹកចិត្ត និងវិធានការទាំងឡាយដែលបានដាក់ចេញសំរាប់គោលបំណងខាងលើរួមមាន :

- ការបង្កើតនីតិវិធីផ្តល់អាជ្ញាប័ណ្ណធនាគារប្រកបដោយតម្លាភាព និងងាយស្រួល រួមមានការផ្តល់អាជ្ញាប័ណ្ណអចិន្ត្រៃយ៍ដល់ស្ថាប័នដែលគោរពតាមបទប្បញ្ញត្តិត្រួតពិនិត្យ ការបញ្ចុះកម្រៃក្នុងការផ្តល់អាជ្ញាប័ណ្ណបើកសាខាថ្មី ការអនុគ្រោះពិសេសលើតម្រូវការដើមទុនសំរាប់ស្ថាប័នហិរញ្ញវត្ថុដែលមានចំណាត់ថ្នាក់ល្អ ហើយចង់បើកជាធនាគារនៅក្នុងប្រទេសកម្ពុជា និងកាត់បន្ថយរយៈពេលក្នុងការធ្វើនីតិវិធី
- ការផ្តល់ការប្រាក់ពេញលេញសំរាប់ប្រាក់បញ្ញើធានាដើមទុន និងផ្តល់ការប្រាក់មួយផ្នែកសំរាប់ប្រាក់បម្រុងកាតព្វកិច្ច
- ពុំមានការរឹតត្បិតលើការផ្ទេរប្រាក់ចំណេញ ។

ចំពោះក្របខ័ណ្ឌច្បាប់ដែលស្ថិតក្រោមការរៀបចំរបស់ធនាគារជាតិនៃកម្ពុជាមាន : ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ និងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ លើសពីនេះទៀត ខណៈដែលយើងកំពុងរង់ចាំការអនុម័តលើច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ បទប្បញ្ញត្តិស្តីពីភតិសន្យាហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយដើម្បីអនុញ្ញាតឱ្យធនាគារពាណិជ្ជអាចអនុវត្តភតិសន្យាហិរញ្ញវត្ថុបាន ។

អាស្រ័យដោយកំណែទំរង់ទាំងឡាយនោះ អន្តរការីយកម្មហិរញ្ញវត្ថុមានភាពប្រសើរឡើងជាលំដាប់ ។

**ចំពោះសំនួរ តើអាជ្ញាធរកំពុងមានសកម្មភាពអ្វីខ្លះ ដើម្បីជំរុញទំនុកចិត្តបន្ថែមទៀតលើវិស័យហិរញ្ញវត្ថុ? ខ្ញុំសូមជូនមតិដូចតទៅ :**

ជានិច្ចជាកាល សកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាគឺសំដៅខិតខំកសាងទំនុកចិត្តរបស់សាធារណជនលើគោលនយោបាយរូបិយវត្ថុ និងប្រព័ន្ធធនាគារ ។

នៅលើទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច ការរក្សាស្ថិរភាពម៉ាក្រូនឹងបន្តជាផ្នែកសំខាន់មួយនៃសកម្មភាពអាទិភាពរបស់ធនាគារជាតិ។ ក្នុងនោះរួមមាន ការរក្សាស្ថិរភាពថ្លៃនិងតម្លៃរូបិយវត្ថុជាតិ ព្រមទាំងការពូនគរទុនបំរុងអន្តរ-ជាតិ ។ មកទល់បច្ចុប្បន្ននេះ ទោះបីមានវិបត្តិជាសកលក្តី រូបិយវត្ថុជាតិបានធ្លាក់ថ្លៃត្រឹមប្រមាណ ២,៥% ឯទុនបំរុងអន្តរជាតិនាដំណាច់ឆ្នាំ២០០៨មានកំរិតស្មើនឹង ៣,៩ ខែនៃការនាំចូលទំនិញ។ សម្ពាធអតិផរណាបានថមថយដោយការទ្រទ្រង់មួយផ្នែកពីគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន និងដោយសារការធ្លាក់ថ្លៃអន្តរជាតិ ។ នៅ

ចំពោះមុខការប្រែប្រួលនៃថ្លៃលើទីផ្សារអន្តរជាតិ ធនាគារជាតិបន្តតាមដានយ៉ាងខ្ជាប់ខ្ជួននូវចលនាថ្លៃ ដែលអាចបង្កហានិភ័យចំពោះអតិផរណា និងដើម្បីធានាថា នយោបាយរូបិយវត្ថុមានសង្គតិភាពសមស្របជាមួយនឹងសន្ទុះកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

ការខិតខំទីពីររបស់ធនាគារជាតិនៃកម្ពុជាក្នុងការជំរុញទំនុកចិត្តរបស់សាធារណជនគឺ ការរក្សាស្ថិរភាពប្រព័ន្ធធនាគារ ។ ធនាគារជាតិបន្តបំពេញការងារនេះតាមរយៈការតាមដានជាប្រចាំលើធនាគារនិងប្រព័ន្ធទូទាត់និងផាត់ទាត់ ។ ជាពិសេស ក្នុងអំឡុងពេលមានការប្រែប្រួលដ៏លឿនដែលបង្កផលប៉ះពាល់ដល់វិស័យហិរញ្ញវត្ថុទូទាំងពិភពលោក ការត្រួតពិនិត្យប្រុងប្រយ័ត្នត្រូវបានពង្រឹងបន្ថែមទៀត ជាមួយនឹងការតំរូវឱ្យបណ្តាធនាគារគោរពតាមច្បាប់/បទប្បញ្ញត្តិចាំបាច់នានាយ៉ាងម៉ត់ចត់ និងការតាមដានជាប្រចាំលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ដោយប្រើវិធីសាស្ត្រប្រាក់បំរុងកាតព្វកិច្ចថ្មី ។ ការត្រួតពិនិត្យដល់ទីកន្លែង និងលើឯកសារ ត្រូវបានពង្រឹងដោយប្រើវិធីសាស្ត្រ CAMELS និងប្រព័ន្ធប៉ាន់ស្មានហានិភ័យទុកជាមុន ហៅថា COBRA ។

ក្នុងខណៈពេលដែលកំពុងមានវិបត្តិពិភពលោកនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតសេវាឥណទានវិបារូប ដើម្បីជួយធនាគារពាណិជ្ជណាដែលមានបញ្ហាសាច់ប្រាក់ងាយស្រួលជាបណ្តោះអាសន្ន ។ បន្ថែមលើនេះទៀត ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងពិចារណាលើការបង្កើតគំរោងត្រៀមគ្រាបន្ទាន់មួយសំរាប់ដោះស្រាយវិបត្តិធនាគារ និងហិរញ្ញវត្ថុក្នុងករណីចាំបាច់ ។

មុននឹងបញ្ចប់ ខ្ញុំមានសេចក្តីសោមនស្សសូមឆ្លៀតឱកាសនេះ ជំរាបជូនអង្គប្រជុំតុមូលថា ជារួម ប្រព័ន្ធធនាគារនៅកម្ពុជាពុំទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិឥណទាននិក្ខេបជាសកលឡើយ ។ ទោះជាដូច្នេះក្តី ធនាគារជាតិនៅតែបន្តការប្រុងប្រយ័ត្នខ្ពស់លើការងារត្រួតពិនិត្យ ។

ជាបញ្ចប់ ខ្ញុំសូមសំដែងការគោរពអរគុណដ៏ជ្រាលជ្រៅចំពោះអ្នករៀបចំវេទិកានេះ និងសូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កំលាំងមាំមួន និងទទួលបានជ័យជំនះគ្រប់ភារកិច្ចជានិច្ច ។

សូមអរគុណ!

## Remark by H.E. Neav Chanthana, Deputy Governor of the National Bank of Cambodia

On the occasion of the Economist Conferences
Siem Reap, 16 February 2009

Senior Ministers, Ministers,
Respected Members of this gatherings,

I am very honored to participate in this important forum today, which has been officiated by Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister of RGC, on an appropriate topic at the time and to audience who would be the catalysts of change as the Cambodian economy is navigating through this critical time.

First, I would like to highlight the roles of the NBC which is to maintain price stability and to develop a sound financial system to support sustainable economic growth.

I am now moving to the first issue: **How to offset growing inflation and an increase in commodity prices, particularly of oil?**

In general, monetary policy seeks to respond to demand-side rather than supply-side inflationary pressures. Therefore, the reasons for price increase need to be clearly understood. In Cambodia, the economy started to be challenged by strong inflationary pressures since December 2007 when the year on year inflation rate posted a double digit increase once again since it was last seen during the 1997-98 Asian crises. The escalating international food and especially energy prices exacerbated inflationary pressures worldwide. As a small, open economy, Cambodia is particularly sensitive to price developments in the world economy, and due to total dependence on external supply of energy source, such development has unquestionably an impact on our inflation performance. The annual inflation rate peaked at record high of 25.7% in May 2008. Food price, the main driver of inflation, rose by 49% in the corresponding period.

Meanwhile, higher than expected monetary expansion as a result of continued large capital flows and the success in the economic management over the last decade, has been also seen as a contributor to rising inflation. Under such reasoning, the sharp rise in inflation prompted a more prudent management of prevailing monetary conditions to allow monetary policy to be better placed to respond to risks of higher inflation. Hence, the monetary policy implementation was focused on managing the excess liquidity position and to avoid the over-involvement of banks in the real estate sector that could have adverse consequences for them. A series of restrictive packages have been introduced to curb the booming credit activity and slowing the growing monetary base, including the increase of the statutory reserve requirement from 8% to 16%, and the ceiling of 15% on banks to limit their lending to real estate sector.

In contrast, risks of high inflation arising from international oil price shock, and if the shock is permanent, would be a daunting challenges for monetary policy of net oil importers such as Cambodia. The monetary policy needs to be flexible and mindful of the second round effects of costs increase. It needs also, on the other hand, to actively support the government measures to address more directly the supply-side risks, particularly in the case of prices of basic food. Attempts to enhance microfinance networks and increase financial outreach to SMEs and farmers to improve agricultural production have been and continue to be part of the NBC's policy considerations.

Excellencies, ladies and gentlemen!

**Allow me now to share a few thoughts to the question: Is Cambodia's economy ready to move away from "dollarisation" and what will this mean for business ?**

The use of US dollar in the territory of Cambodia dated backed more than a decade ago. It should be noted that such use has never been an outcome of policy decision of the RGC but reflected the preference of the market participants for a substitution currency to the domestic one given the economic difficulties facing the country at that time. Once people get used to the conveniences of using hard currency, there seems to be a build-in resistance to reverse the process, even after the macroeconomic conditions have been improved. It would take long time to adjust people's behavior.

Over the past years, the NBC has performed numerous efforts to manage the exchange rate of the Riel against USD with the objective of enhancing public confidence in the local currency and smoothly and progressively extend the share of the Riel in the economic exchanges. Although progress could be deemed very slow for economic observers, it is stressed that 1) the NBC's action has allowed for stabilizing the value of the Riel against USD and 2) that, even in urban area, the Riel is fully accepted in daily transactions and at the current exchange rate. In addition, buy/sell spreads – or commissions – have become narrower which is clearly positive since it points at a greater confidence in our national currency and in the Central Bank's action to manage a realistic exchange-rate against the US dollar.

The present monetary regime affects individual consumers and business differently, depending on the currency denomination of their income or the transactions involved in their business activities. I prefer thus to answer to the earlier posted question with another question: Does the use of the US dollar in the Cambodian economy so far present any problems for consumers or companies? From the macro perspective, few will dispute the claim that dollarisation has considerable merit in restoring and supporting economic stability and a sound national financial system in this country through re-monetization and financial deepening, while macroeconomic costs such as lost of seignorage and constrains to monetary policy are also not deniable.

Now, as the shockwaves of the financial turbulence have hit most countries in the world, the flight to quality has noticeably increased the demand for US dollar. Against all the background discussed above, experiences of dollarized economies in several parts of the world showed that de-dollarization cannot be accomplished by rigid legislation, but requires the creation of an environment which stimulates the use of domestic currency by the public and business. Therefore, we think that the most important things to do at this time for Cambodia is to continue to strengthen its fiscal position and the banking system and leverage the foundation of the economy before making any changes in the monetary regime.

**The following discussion deals with the question: What is Cambodia doing to attract investment in its financial services sector?**

I like to focus on three issues: The openness of the financial sector, the role of the Central Bank as monetary and supervisory authority, and the reforms in the financial sector.

First, financial service liberalization is one of the key factors in attracting investments. Cambodia has a quite liberalized investment regime, which is also applicable for the financial sector. So far, we have placed great attention in providing market access and national treatment to foreign investors, where 100% foreign ownership in the banking sector is allowed provided that they comply with all the licensing requirements for banks, which are the same for resident and non-residents of Cambodia. Cambodia is already home to about ten foreign banks branches and subsidiaries. They accounted for 46% and 38%, respectively in the total banks assets and equity.

Second, in the financial sector, the NBC as the monetary and supervisory authority is striving both for being a strong regulator and for operating in a transparent manner. We will make further efforts to insure that financial policies, regulatory framework, procedures and measures relating to the financial services suppliers and markets are publicly disclosed and explained before being adopted. We have greatly valued a frank exchange of views with the private sector, which is fostered by a confidential and cooperative atmosphere.

Third, we understand that financial services are critical for the functioning of the entire economy. And a well-functioning financial system, on the other hand, depends on the legal and regulatory underpinning aimed at harnessing private incentives and at removing deficiencies in markets and operating environment through the reduction of risks and costs of banking operations.

Under this spirit, it is envisaged that the financial reforms now in progress and under consideration, as described in the financial sector blueprint for the long-term development of the banking sector, which was adopted in 2001 and updated in 2007, will make financial intermediation more efficient and attracting more investment, by improving legal and financial infrastructure, and increasing competition among banks and other financial institutions.

Incentives and measures that have been introduced for the above purposed included:

- Introducing a transparent and simplified banks licensing procedures, including the provision of a permanent license to institutions that meet supervisory requirements; the licensing of new branches at discounted fees, a special favor on capital requirement for financial institutions with good rating that wish to open banking business in Cambodia, and shorter processing time;
- A full remuneration of capital guarantee deposits and a partial remuneration of statutory reserve requirement;
- No restriction on remittance of profits.

On regulatory framework, we have adopted two importance laws: the Negotiable Instruments and Payment Transactions Law, the Law on Anti-Money Laundering and Counter Financing of Terrorism. Besides, while we are awaiting the Law on financial leasing to be passed, a regulation on financial lease has been issued to allow banks to conduct financial leasing.

Thanks to the reforms so far, financial intermediation has been improved remarkably.

On the question: **What is being done to stimulate greater public trust in the financial sector?** I would like to highlight some points as follows:

The actions of the NBC have been always a concerted attempt to build public trust in the monetary policy and in the banking sector.

On macroeconomic front, maintaining macroeconomic stability will continue to be an important part of our priority actions. Those include monitoring a low level of inflation, safeguarding the value of the national currency, and enlarging the country's international reserves. So far, despite the global turbulence, our national currency remained broadly stable; depreciating by only about 2.5%, while international reserves have reached a level that is sufficient to cover about 3.9 months of imports. Inflation has been subdues, underpinned by prudent monetary policy and easing international prices of goods and energy. Due to the uncertain development in the world market, the NBC is closely monitoring movements that could pose upside risks to the inflation outlook, including emerging trends in global commodity prices, to ensure that the monetary policy stance remains consistent with the economy's momentum for sustained growth.

Turning now to the second thrust of the NBC in dealing with public confidence, which is to maintain the stability in the banking system. The NBC is doing this through regular monitoring of banks and the payment and settlement system. Particularly during this period of rapid change affecting financial sector around the globe, bank prudential supervision is strengthening further, and the stricter enforcement of banks compliance with the laws and regulations, closer monitoring of bank liquidity using new methodology of reserve requirement. On-site and offsite supervision has been enhanced using CAMELS methodology and a more proactive risk assessment approach called COBRA.

Within the context of global turbulence, NBC set up an overdraft facility to help banks that have temporary liquidity problem. In addition, NBC and MEF are now considering establishing a contingency plan to deal with banking and financial distress as such condition arises.

To conclude, the NBC is very pleased to take this opportunity to inform the audience that, by and large, our banking sector has no direct exposure to global sub prime mortgage crisis. In spite of this, the NBC is committed to remain vigilant in the supervision area.

Last but not least, I would like to express my profound gratitude to the organizers of this forum**,** and allow me to wish you all happiness and success in your endeavors.

Thank You!!!

Deputy Governor